ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈនៃការយោគយល់

រវាង

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

និង

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)

ស្តីពី

សកម្មភាពបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់
(ការកេងប្រវ័ញ្ចកម្លាំងពលកម្ម) ក្នុងបរិបទទេសន្តរប្រវេសន៍

២០២៥-២០២៨

# បុព្វកថា

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ដែលតទៅនេះកំណត់ហៅថា "គូភាគី"

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានឆន្ទៈក្នុងកិច្ចរួមសហប្រតិបត្តិការជាមួយនឹងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ដែលមានសកម្មភាពបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ (ការកេងប្រវ័ញ្ចកម្លាំងពលកម្ម) ក្នុងបរិបទទេសន្តប្រវេសន៍ ។

- ដោយមានបំណងធ្វើកិច្ចសហប្រតិបត្តិការ លើការងារមនុស្សធម៌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈ តាមរយៈការពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) និងមន្ត្រីមូលដ្ឋានជួរមុខ ដើម្បីជានាឱ្យមានការឆ្លើយតប និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ចំពោះអំពើជួញដូរមនុស្សនៅថ្នាក់ក្រោមជាតិ និងការសហការជាមួយបណ្តាញជនធ្លាប់រងគ្រោះក្នុងស្រុក និងសហគមន៍ ។

**គូភាគីបានព្រមព្រៀងគ្នាដូចតទៅ៖**

## ប្រការ១
## គោលបំណង

អនុស្សរណៈនៃការយោគយល់នេះ មានគោលបំណងកំណត់បែបបទ និងនីតិវិធីសម្រាប់កិច្ចសហប្រតិបត្តិការរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ដើម្បីពង្រឹងសមត្ថភាព និងការសម្របសម្រួលរបស់គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ដោយមានការចូលរួមជាមួយភាគីពាក់ព័ន្ធដទៃទៀត ព្រមទាំងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងការការពារពលករក្នុងបរិបទ ទេសន្តប្រវេសន៍ ។

## ប្រការ២
## វិសាលភាពនៃកិច្ចសហប្រតិបត្តិការ

វិសាលភាព នៃកិច្ចសហប្រតិបត្តិការ ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈតាមរយៈគម្រោងពង្រឹងសមត្ថភាពគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ដើម្បីការពារពលករក្នុងបរិបទទេសន្តប្រវេសន៍ ។

**សង្ខេបសកម្មភាពគម្រោង៖**

១. ប៉ាន់ប្រមាណ និងធ្វើផែនការ

- ប្រជុំជាមួយអភិបាល នៃគណៈអភិបាលខេត្ត និងថ្នាក់ដឹកនាំគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ)

- ប៉ាន់ប្រមាណតម្រូវការ និងវាស់ស្ទង់សមត្ថភាព
- សម្របសម្រួលជាមួយនឹងអ្នកពាក់ព័ន្ធ ដើម្បីបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញ

២. ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីជួរមុខ ថ្នាក់ក្រោមជាតិ នៃក្រុមការងារទាំង៦ (គ.ខ.ប.ជ) ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ជំនាញស្រាវជ្រាវករណីជួញដូរមនុស្ស ដោយប្រើប្រាស់សៀវភៅលំហាត់អនុវត្តនៃរឿងក្តីជួញដូរមនុស្ស ការថែទាំ ការប៉ះទង្គិចផ្លូវចិត្ត ការគ្រប់គ្រងករណី និងវគ្គបណ្តុះបណ្តាលនានា ដើម្បីឆ្លើយតបនឹងការប៉ាន់ប្រមាណ ឬការវាស់ស្ទង់សមត្ថភាព

៣. ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកលេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ស្តីពីតួនាទីភារកិច្ច និងការទទួលខុសត្រូវក្នុងការធ្វើផែនការសកម្មភាព ការធ្វើរបាយការណ៍ និងការតាមដានត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងការស្វែងរកធនធាន

៤. វគ្គបណ្តុះបណ្តាល ត្រួតពិនិត្យលទ្ធផលពាក់កណ្តាលឆ្នាំ

៥. រៀបចំទស្សនកិច្ចសិក្សា ស្តីពីសកម្មភាពបង្ការទប់ស្កាត់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ (ការកេងប្រវ័ញ្ចកម្លាំងពលកម្ម) ក្នុងបរិបទទេសន្តរប្រវេសន៍ ដើម្បីពង្រឹងការសម្របសម្រួលកិច្ចសហការ ការលើកកម្ពស់ ការចែករំលែកព័ត៌មាន និងការអនុវត្តល្អៗ

៦. សម្របសម្រួលការឆ្លើយតបរបស់លេខាធិការដ្ឋានទៅនឹងចំណុច ខ្វះខាតនានា តាមរយៈសិក្ខាសាលា ដោយប្រើវិធីសាស្ត្រពិនិត្យមើលលើសកម្មភាពដែលបានអនុវត្ត ការឆ្លុះបញ្ចាំង ការរៀនពីបទពិសោធន៍កន្លងមក និងការធ្វើផែនការបន្ត

៧. ផ្សព្វផ្សាយពីគោលនយោបាយថ្នាក់ជាតិ ដូចជាការកំណត់អត្តសញ្ញាណ នីតិវិធីបញ្ជូនបន្ត និងស្តង់ដារនីតិវិធីប្រតិបត្តិ(SOP)

៨. ផ្សារភ្ជាប់ទំនាក់ទំនងរវាងលេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ជាមួយសហគមន៍ និងជនធ្លាប់រងគ្រោះ ដើម្បីចូលរួមផ្សព្វផ្សាយក្នុងសហគមន៍គោលដៅអំពីភាពងាយរងគ្រោះមកពីការធ្វើទេសន្តរប្រវេសន៍ ព្រមទាំងចូលរួមស្វែងយល់ និងពង្រឹងការជឿជាក់លើប្រព័ន្ធយុត្តិធម៌

៩. សហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) លើការត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពគម្រោង នៅក្នុងខេត្តកំពង់ធំ កំពង់ចាម និងបន្ទាយមានជ័យ

១០. ពង្រីកសកម្មភាពគម្រោងទៅខេត្តបាត់ដំបង ព្រៃវែង និងត្បូងឃ្មុំនៅដើមឆ្នាំទី៣

១១. ធ្វើរបាយការណ៍បូកសរុបប្រចាំឆ្នាំ ស្តីពីលទ្ធផលនៃការអនុវត្តអនុស្សរណៈ និងលើកទិសដៅបន្ត ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីឧត្តមានុវត្តន៍នៃគម្រោង ដើម្បីចែករំលែកទៅដៃគូពាក់ព័ន្ធដទៃទៀត ។

## ប្រការ៣

## ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានព្រមព្រៀងដូចខាងក្រោម៖

ក. អនុញ្ញាតឱ្យអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ធ្វើកិច្ចសហប្រតិបត្តិការក្នុងគោលដៅប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដោយអនុវត្តទៅតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៃព្រះរាជាណាចក្រកម្ពុជា

ខ. ដាក់ចេញនូវគោលការណ៍ណែនាំ ជូនដល់គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ព្រមទាំងរដ្ឋបាលខេត្តពាក់ព័ន្ធដោយសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ដែលធ្វើសកម្មភាពនៅក្នុងភូមិសាស្ត្ររបស់ខ្លួន

គ. សម្របសម្រួលទទួលព័ត៌មាន និងរបាយការណ៍ពីអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ស្ដីពីសកម្មភាព លទ្ធផល និងបទពិសោធន៍ ឬភាពប្រឈមនានាដែលត្រូវរួមគ្នាដោះស្រាយ

ឃ. សហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) រៀបចំកិច្ចប្រជុំបច្ចេកទេស និងផ្សព្វផ្សាយអំពីការអនុវត្តអនុស្សរណៈ ដល់អង្គការដៃគូរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ជាមួយគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ)

ង. អនុញ្ញាតឱ្យអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) និងអង្គការដៃគូពាក់ព័ន្ធការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់រៀបចំផែនការជាតិ គោលនយោបាយ ឬលិខិតបទដ្ឋានចាំបាច់នានា ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)

ច. រៀបចំកិច្ចប្រជុំត្រីមាស និងកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់ ដើម្បីតាមដានភាពរីកចម្រើនក្នុងការអនុវត្តគម្រោង ភាពប្រឈមដែលត្រូវដោះស្រាយ និងចែករំលែកនូវបទពិសោធន៍ដែលទទួលបានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

## ប្រការ៤

## ការទទួលខុសត្រូវរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)

អង្គការIJM បានព្រមព្រៀងដូចខាងក្រោម៖

ក. គ្រប់គ្រងថវិកា ដើម្បីអនុវត្តសកម្មភាពរបស់គម្រោងឱ្យមានប្រសិទ្ធភាពតាមគោលដៅ និងគោរពយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា

ខ. មិនអនុញ្ញាតឱ្យភ្នាក់ងាររបស់ខ្លួនចូលរួមនូវរាល់សកម្មភាពទាំងឡាយណា ដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្ដាប់ធ្នាប់សង្គម ឬសកម្មភាពនយោបាយដទៃទៀតដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា

គ. ប្រតិបត្តិនូវរាល់សកម្មភាពមនុស្សធម៌ ជួយដល់ជនរងគ្រោះ ជនធ្លាប់រងគ្រោះ និងងាយរងគ្រោះ (ស្ត្រី និងកុមារ) ស្របតាមផែនការសកម្មភាព និងគោលនយោបាយរបស់ខ្លួន ដោយអនុលោមតាមខ្លឹមសារនៃអនុស្សរណៈ និងប្រកាន់ខ្ជាប់នូវគោលការណ៍នៃកិច្ចសហប្រតិបត្តិការ

ឃ. ពង្រឹងភាពជាដៃគូជាមួយនឹងលេខាធិការដ្ឋាននៃ គ.ខ.ប.ជ តាមរយៈអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីសម្របសម្រួលដល់ការផ្លាស់ប្តូរព័ត៌មានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងសកម្មភាពដែលបានអនុវត្ត និងទិសដៅបន្តដែលមានចែងក្នុងអនុស្សរណៈនេះ

ង. ចូលរួមសកម្មភាពជាមួយអគ្គលេខាធិការដ្ឋាននៃគ.ជ.ប.ជ និងលេខាធិការដ្ឋាន គ.ខ.ប.ជ សហគមន៍ និងជនធ្លាប់រងគ្រោះក្នុងខេត្តគោលដៅរបស់គម្រោង ដើម្បីបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ជាពិសេសការកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងបរិបទទេសន្តរប្រវេសន៍

ច. ផ្តល់ព័ត៌មាន និងរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ អំពីសកម្មភាព និងលទ្ធផលដែលបានអនុវត្ត មកអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ. និង គ.ខ.ប.ជ. (ចំពោះខេត្តគោលដៅទាំង៦)

ឆ. ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ គ.ជ.ប.ជ. និង គ.ខ.ប.ជ. ស្តីពីការផ្លាស់ប្តូរណាមួយទាក់ទងនឹងអាសយដ្ឋាន អ្នកតំណាង និងប្រធានគម្រោងដែលបានចាត់តាំង។

## ប្រការ៥
## ការដោះស្រាយវិវាទ

រាល់វិវាទដែលកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តអនុស្សរណៈនេះត្រូវដោះស្រាយជាបន្ទាន់ដោយសន្តិវិធីតាមរយៈការពិគ្រោះយោបល់ ឬតាមមធ្យោបាយផ្សេងទៀតដែលគូភាគីព្រមព្រៀង។

## ប្រការ៦
## ការធ្វើវិសោធនកម្ម

អនុស្សរណៈនៃការយោគយល់នេះ អាចធ្វើវិសោធនកម្ម និងកែសម្រួលឡើងវិញ ផ្អែកតាមការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងគូភាគី។

ការធ្វើវិសោធនកម្មនឹងចូលជាធរមានតាមកាលបរិច្ឆេទដែលកំណត់ដោយគូភាគី ហើយនឹងក្លាយជាផ្នែកបំពេញបន្ថែមនៃអនុស្សរណៈនៃការយោគយល់នេះ។

## ប្រការ៧
## សុពលភាព

អនុស្សរណៈនៃការយោគយល់នេះមានសុពលភាពរយៈពេល០៣(បី)ឆ្នាំ ហើយនឹងអាចបន្តសុពលភាពបានដោយមានការព្រមព្រៀងពីគូភាគី។

# ប្រការ៨

## ការចូលជាធរមាន និងការបញ្ចប់

អនុស្សរណៈនៃការយោគយល់នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា។

អនុស្សរណៈនៃការយោគយល់នេះ អាចត្រូវបានបញ្ចប់ដោយភាគីណាមួយក៏បាន ដោយការជូនដំណឹងអំពីបំណងបញ្ចប់ការអនុវត្តអនុស្សរណៈនៃការយោគយល់នេះ ជូនភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ អនុស្សរណៈនៃការយោគយល់នេះ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០(ហុកសិប)គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។

អនុស្សរណៈនៃការយោគយល់នេះធ្វើឡើងជាភាសាខ្មែរ ចំនួន ០២(ពីរ)ច្បាប់ដើម និងពុំមែនជាកិច្ចព្រមព្រៀង បង្កើតសិទ្ធិ និងកាតព្វកិច្ចណាមួយឡើយ។

ចុះហត្ថលេខានៅថ្ងៃទី...១៤.....ខែ..កញ្ញា....ឆ្នាំ២០២៥។

**ជ.គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**

**ជ.អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)**
**នាយកប្រចាំប្រទេស**

IJM

**ជុំ សាឯម**

## ឧបសម្ព័ន្ធ

## សេចក្តីបរិយាយអំពីគម្រោង

| | | |
|---|---|---|
| ឈ្មោះស្ថាប័ន | ៖ | អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) |
| ប្រភេទស្ថាប័ន | ៖ | អង្គការមិនមែនរដ្ឋាភិបាលបរទេស |
| លិខិតអនុញ្ញាត | ៖ | អនុស្សរណៈ រវាងអង្គការ International Justice Mission និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤។ |
| | ៖ | អនុស្សរណៈនៃការយោគយល់រវាងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) និងក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការចូលរួមសកម្មភាពមនុស្សធម៌ នៅព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២។ |
| អាសយដ្ឋាន | ៖ | ផ្ទះលេខ ៣៧ ផ្លូវលេខ ៥៩៤ ភូមិ ៣ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា។ |
| លេខទូរសព្ទទំនាក់ទំនង | ៖ | ០២៣ ៩៩១ ៤២០ |
| អ៊ីម៉ែល | ៖ | cambodia@ijm.org |
| ឈ្មោះគម្រោងសកម្មភាព | ៖ | សកម្មភាពបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ (ការកេងប្រវ័ញ្ចកម្លាំងពលកម្ម) ក្នុងបរិបទទេសន្តរប្រវេសន៍។ |
| ទីតាំងគម្រោង | ៖ | ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ (នឹងពង្រីកទីតាំងគម្រោងទៅខេត្តបាត់ដំបង ខេត្តត្បូងឃ្មុំ និងខេត្តព្រៃវែង នៅដើមឆ្នាំទី៣)។ |
| ដៃគូអនុវត្តគម្រោង | ៖ | សហការជាមួយនឹងអង្គការដៃគូ នៅក្នុងខេត្តគោលដៅដែលមានសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |
| ថវិកាអនុវត្តន៍គម្រោង | ៖ | ១៨០,000 ដុល្លារ (មួយរយប៉ែតសិបពាន់ដុល្លារ) អាម៉េរិក រយៈពេល០៣ឆ្នាំ |
| អ្នកផ្តល់ថវិកាគាំទ្រគម្រោង | ៖ | នៅការិយាល័យកណ្តាលរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ប្រចាំសហរដ្ឋអាម៉េរិក |
| កាលបរិច្ឆេទចាប់ផ្តើម | ៖ | ឆ្នាំ២០២៥ |
| កាលបរិច្ឆេទបញ្ចប់ | ៖ | ឆ្នាំ២០២៨ |
| ចំនួនបុគ្គលិកខ្មែរ | ៖ | បច្ចុប្បន្នមានចំនួន ១២នាក់ (ស្រី ៣នាក់) |
| ចំនួនបុគ្គលិកបរទេស | ៖ | គ្មាន |